01340778

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**D298/2/1/3**

*តាងនាមប្រជារាស្ត្រខ្មែរ និងអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងលេខ៖** ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៨)

**អង្គបុរេជំនុំជម្រះ**

**សមាសភាព៖**
ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ី ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ៖** ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 10 / 2016
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សំងាត់**

**សេចក្តីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឲ្យធ្វើមោឃភាពប្រតិចារឹក និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី**

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីរបស់ អ៊ឹម ចែម៖**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
មេធាវី ជេត វណ្ណលី
មេធាវី ហុង គីមសួន
មេធាវី គីម ម៉េងឃី

មេធាវី ប៊ិត សៀងលីម

មេធាវី Wayne JORDASH

មេធាវី ឡោ ជុនធី

មេធាវី សំ សុគង់

មេធាវី ស៊ិន សុវ៉ន

មេធាវី ទី ស្រីនណា

មេធាវី វ៉ែន ពៅ

មេធាវី Linda BEHNKE

មេធាវី Laure DESFORGES

មេធាវី Herve DIAKIESE

មេធាវី Ferdinand DJAMMEN-NZEPA

មេធាវី Nicole DUMAS

មេធាវី Isabelle DURAND

មេធាវី Françoise GAUTRY

មេធាវី Martine JACQUIN

មេធាវី Emmanuel JACOMY

មេធាវី Christine MARTINEAU

មេធាវី Barnabe NEKUI

មេធាវី Lyma NGUYEN

មេធាវី Beini YE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលសំណើសុំធ្វើមោឃភាព មានចំណងជើងថា "សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឲ្យប្ដឹងទៅអង្គបុរេជំនុំជម្រះ សុំឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារឹក និងកំណត់ហេតុជាលាយល័ក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីមួយចំនួន" ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("សំណើសុំធ្វើមោឃភាព")[1] ហើយដែលត្រូវបានដាក់ដោយសហមេធាវីការពារក្ដី ("សហមេធាវី") អ៊ឹម ចែម ("អ្នកស្នើសុំ")។

## I. សេចក្ដីផ្ដើម

1. សំណើសុំធ្វើមោឃភាពមួយផ្នែក ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ជូនទៅអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦[2] អនុលោមតាមវិធាន ៧៦(៣) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទក្លែងបន្លំកិច្ចស៊ើបសួរចំនួនបួន ទាក់ទងនឹងការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត[3] និងកំណត់ហេតុស្ដាប់ចម្លើយសាក្សី យក់ នាម ចំនួនពីរ[4]។

## II. រំឭកប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបម្រុង បានបញ្ជូនទៅកាន់

---

[1] សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឲ្យប្ដឹងទៅអង្គបុរេជំនុំជម្រះ សុំឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារឹក និងកំណត់ហេតុជាលាយល័ក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីមួយចំនួន ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D298 ("សំណើសុំធ្វើមោឃភាព")។

[2] ដីកាសម្រេចលើពាក្យសុំរបស់ អ៊ឹម ចែម ស្នើឲ្យប្ដឹងទៅអង្គបុរេជំនុំជម្រះ សុំឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពប្រតិចារឹក និងកំណត់ហេតុនៃការស្ដាប់ចម្លើយ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D298/2 ("ដីកាសម្រេចបញ្ជូនសំណើសុំ")។

[3] កំណត់ហេតុស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ឯកសារ D85/5.1.4.2 , កំណត់ហេតុស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D101/1.1, ថាសសំឡេងនៃកំណត់ហេតុស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D101/1.1R, ប្រតិចារឹកចារឹកកិច្ចសម្ភាសន៍ជាមួយ ប៉ោ បណ្ដែត ដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ D85/4.1.5។ *សូមមើល* ឧបសម្ព័ន្ធ "ក" នៃដីកាសម្រេចបញ្ជូនសំណើសុំ។

[4] កំណត់ហេតុស្ដាប់ចម្លើយសាក្សី យក់ នាម ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D219/140 ("កំណត់ហេតុ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥"), កំណត់ហេតុស្ដាប់ចម្លើយសាក្សី យក់ នាម ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D219/141។ *សូមមើល* ឧបសម្ព័ន្ធ "ក" នៃដីកាសម្រេចបញ្ជូនសំណើសុំ។

ការិយាល័យសហចៅក្រមស៊ើបអង្កេត នូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ដែលចោទប្រកាន់ការទទួលខុសត្រូវរបស់អ្នកស្នើសុំ ចំពោះឧក្រិដ្ឋកម្មមួយចំនួន ដែលស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ[5]។ ការចោទប្រកាន់ផ្សេងៗទៀត ត្រូវបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចំនួនពីរ[6]។

3. នៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១១ សាក្សី យក់ នាម ទំនងជាបានប្រកាសប្រាប់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថាមានមនុស្សបីនាក់[7] បានទាក់ទងមកគាត់ ក្រោយពីគាត់បានបញ្ចប់ការផ្ដល់ចម្លើយដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ BLUNK កាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១[8]។

4. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ BLUNK បានសម្រេចបើកការស៊ើបសួរផ្ទៃក្នុង អនុលោមតាមវិធាន ៣៥(២)(ខ) លើបទជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយពិចារណាឃើញថាខ្លួន "មានហេតុផលជឿថា" ទំនងជាមានមនុស្សមួយចំនួន បានព្យាយាមជះឥទ្ធិពលលើសាក្សីមួយចំនួន ក្នុងនោះមានសាក្សី យក់ នាម ក្នុងអំឡុងពេលនៃការស្ដាប់ចម្លើយក្រៅផ្លូវការ[9]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសចំនួនបី ដែលបានផ្ទេរសិទ្ធិឲ្យធ្វើការស៊ើបអង្កេតលើបទជ្រៀតជ្រែកចូលក្នុង

[5] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1, សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[6] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានា នៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D65, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ អំពើហិង្សាយេនឌ័រ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191។

[7] មជ្ឈមណ្ឌលឯកសារកម្ពុជា៖ កិច្ចសម្ភាសន៍ជាមួយ EL Pheap យក់ នាម BIN Nann, RIN Kheng និង ធិប សំផាត់។ កំណត់ត្រានៃការចុះដល់ទីកន្លែង ដោយ ឡុង ដានី ១០-១១ កញ្ញា ២០១១ អាចរកបាននៅលើគេហទំព័រ www.dccam.org និងត្រូវបានដាក់ចូលក្នុងសំណុំរឿង ដោយមានលេខសម្គាល់ D115/1.1 ("របាយការណ៍ចុះពិនិត្យដល់ទីកន្លែង របស់ DC-Cam")។ *សូមមើលផងដែរ* ដីកាសម្រេចបញ្ជូនសំណើសុំ កថាខណ្ឌ ៤ និងកំណត់សម្គាល់ជើងទំព័រ ៥។

[8] កំណត់ហេតុស្ដាប់ចម្លើយសាក្សី យក់ នាម ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ D43។

[9] ដីកាសម្រេចស្ដីអំពីការបើកការស៊ើបសួរលើការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ ក្រោមបទប្បញ្ញត្តិនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D85 ("ដីកាសម្រេចបើកការស៊ើបអង្កេត")។

01340782



កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ និងមានការចុះកាលបរិច្ឆេទជាបន្តបន្ទាប់ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១[10] ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ ("ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២")[11] និងថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២[12]។

5. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ដីកាចាត់ឱ្យស៊ើបសួរជំនួសលើអង្គសេចក្តី ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ដែលបានផ្ទេរសិទ្ធិដឹកនាំធ្វើការស្តាប់ចម្លើយសាក្សី ក្នុងនោះមានសាក្សី ប៉ោ បណ្តែត ផងដែរ ("ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១")[13] ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ដោយមានភ្ជាប់ជាមួយនូវរបាយការណ៍អនុវត្តដីកានេះ[14] និងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានលើកឡើង ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ ("កំណត់ហេតុ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១")[15]។

6. ពាក់ព័ន្ធនឹងការស៊ើបអង្កេតលើបទជ្រៀតជ្រែកចូលក្នុងដំណើរការយុត្តិធម៌ នៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត បានប្រគល់របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ ("របាយការណ៍អ្នកស៊ើបអង្កេត")[16]។ ក្នុងក្របខណ្ឌនេះ កំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ចំនួនមួយ ដែលគ្មានចុះហត្ថលេខា និងចុះកាលបរិច្ឆេទថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ("កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១")[17] ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង។

7. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងលោក KASPER-

---

[10] ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D85/1.1។ *សូមមើលផងដែរ Decision to Correct the Rogatory Letter dated 19 September 2011* ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារ D85.1។

[11] ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ ឯកសារ D85/2 និងត្រូវបានកែប្រែដោយ ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារ D85/2/1។

[12] ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារ D85/3។

[13] ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ឯកសារ D101។

[14] របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ D101/1។

[15] *សូមមើលខាងលើ* កំណត់សម្គាល់ជើងទំព័រ ៣។

[16] របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ឯកសារ D85/5.1.1 ("របាយការណ៍អ្នកស៊ើបអង្កេត")។

[17] *សូមមើលខាងលើ* កំណត់សម្គាល់ជើងទំព័រ ៣។

ANSERMET បានប្រគល់ជូនអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នូវលទ្ធផលនៃការស៊ើបអង្កេត ទាក់ទងនឹងបទជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[18]។

8. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចដាក់អ្នកស្នើសុំឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ក្នុងក្របខណ្ឌសំណុំរឿង ០០៤[19]។

9. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងភាគីពីការបិទបញ្ចប់ការស៊ើបសួរ ពាក់ព័ន្ធនឹងអ្នកស្នើសុំ[20]។

10. នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេត បានចេញដីកាបំបែកដំណើរការនីតិវិធីពាក់ព័ន្ធនឹងអ្នកស្នើសុំ ចេញពីសំណុំរឿង ០០៤[21]។

11. នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៦ សហមេធាវីការពារអ្នកស្នើសុំ បានដាក់សំណើសុំមោឃភាព ដែលត្រូវបានបំពេញដោយសេចក្តីបន្ថែម នៅថ្ងៃទី ០៣ ខែ មីនា ឆ្នា ២០១៦ ("សេចក្តីបន្ថែម")[22]។

12. នៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ នូវផ្នែកនៃសំណើសុំ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់អំពីបទក្លែងបន្លំកិច្ចនីតិវិធី ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តោត និង យក់ នាម[23]។

13. នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ អនុលោមតាមសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ[24] សហ

---

[18] ដីកាសម្រេចបញ្ជូនបញ្ហាស្តីពីការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ទៅអាជ្ញាធរសមត្ថកិច្ចពាក់ព័ន្ធ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ D85/8 ("ដីកាសម្រេចបញ្ជូនទៅអយ្យការ")។

[19] ដីកាសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D239។

[20] សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង អ៊ឹម ចែម ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D285។

[21] ដីកាសម្រេចបំបែកសំណុំរឿងទាក់ទងនឹង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D286/7។

[22] សេចក្តីបន្ថែមទៅលើការស្នើរបស់អ្នកស្រី អ៊ឹម ចែម ឲ្យដាក់ពាក្យបណ្តឹងទៅអង្គបុរេជំនុំជម្រះ សុំធ្វើមោឃភាពលើប្រតិចារឹក និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីមួយចំនួន ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D298/1 ។

[23] *សូមមើល* ដីកាសម្រេចបញ្ជូនសំណើសុំ។

[24] សារអេឡិកត្រូនិករបស់អង្គបុរេជំនុំជម្រះ ផ្ញើជូនភាគី មានចំណងជើងថា *"NOTIFICATION: Pre-Trial Chamber's Instructions to the parties in Case File N° 004/1/07-09-2009-ECCC/OCIJ (PTC28)"* ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ

មេធាវីបានជូនដំណឹងភាគីថា ខ្លួនសុំត្រឹមរក្សាទុកនូវរាល់ទឡ្ហីករណ៍ទាំងឡាយ ដែលបានលើកឡើងនៅក្នុងសំណើសុំធ្វើមោឃភាព ដូចដែលត្រូវបានដាក់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត[25]។

14. នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានឆ្លើយតបទៅនឹងសំណើសុំធ្វើមោឃភាព ("ចម្លើយតប")[26]។ សហមេធាវីបានឆ្លើយតបទៅសហព្រះរាជអាជ្ញាអន្តរជាតិវិញ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ("ការឆ្លើយតបទៅនឹងចម្លើយតប")[27]។

15. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿង ០០៤/១ ទៅកាន់សហព្រះរាជអាជ្ញា ដើម្បីសុំឱ្យចេញដីកាសន្និដ្ឋានស្ថាពរ[28]។

## III. សំណើឧបត្ថម្ភហេតុរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

16. ដោយយល់ឃើញថា ការបិទបញ្ចប់កិច្ចស៊ើបសួរ មិនគួរត្រូវបានពន្យារពេលយូរពេក ដោយសារតែសំណើសុំមោឃភាពនោះ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំជាលក្ខណៈឧបត្ថម្ភហេតុ ឱ្យអង្គបុរេជំនុំជម្រះ ចេញសេចក្តីសម្រេចមួយ ដោយមានផ្តល់សំអាងហេតុតាមក្រោយ ឬ ជូនដំណឹងដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការបិទបញ្ចប់ការស៊ើបសួរ ដោយមិនបង្អង់យូរ និងបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានស្ថាពរ ("សំណើឧបត្ថម្ភហេតុ")[29]។

---

២០១៦។

[25] សារអេឡិកត្រូនិករបស់អ្នកច្បាប់ក្រុមមេធាវីការពារក្តីរបស់អ្នកស្នើសុំ ផ្ញើជូនអង្គបុរេជំនុំជម្រះ មានចំណងជើងថា *"RE: NOTIFICATION: Pre-Trial Chamber's Instructions to the parties in Case File N° 004/1/07-09-2009-ECCC/OCIJ (PTC28)"* ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦។

[26] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងពាក្យសុំមោឃភាពរបស់ អ៊ឹម ចែម ចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ D298/2/1/1 ("ចម្លើយតប")។

[27] ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីពាក្យស្នើសុំរបស់អ្នកស្រី ឱ្យមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ D298/2/1/2 ("ការឆ្លើយតបទៅនឹងចម្លើយតប")។

[28] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ យោងតាមវិធានផ្ទៃក្នុង ៦៦(៤) ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ឯកសារ D304។

[29] ចម្លើយតប កថាខណ្ឌ ១, ១៥-១៨។

17. សហមេធាវីលើកឡើងថា អនុលោមតាមវិធាន ៦៦ ការបិទការស៊ើបសួរ និងការបញ្ជូនសំណុំរឿង គឺជាអំណាចផ្តាច់មុខរបស់សហចៅក្រមស៊ើបអង្កេត[30]។ សហមេធាវីយល់ឃើញថា អង្គបុរេជំនុំជម្រះមិនអាចស្នើឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត បិទបញ្ចប់ការស៊ើបសួរ មុននឹងដំណើរការនីតិវិធីស្នើសុំមោឃភាព ត្រូវបានសម្រេចរួចរាល់នោះឡើយ[31] ដោយទុកបញ្ហាចោល គ្មានដំណោះស្រាយ ហើយនៅទីបញ្ចប់ វាអាចធ្វើឱ្យមានការពន្យារពេលបន្ថែមទៀត[32]។

18. យោងតាមដីកាចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ដែលតាមរយៈដីកានេះ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿង ០០៤/១ ទៅកាន់សហព្រះរាជអាជ្ញា ដើម្បីស្នើសុំឱ្យដាក់ដីកាសន្និដ្ឋានស្ថាពរ[33] អង្គបុរេជំនុំជម្រះសូមបដិសេធសំណើឧប្បត្តិហេតុ ព្រោះថា សំណើនេះលែងមានសុពលភាព។

## IV. ភាពទទួលយកបាន

19. សហមេធាវី និងសហព្រះរាជអាជ្ញាអន្តរជាតិ ពុំបានលើកឡើងនូវទឡ្ហីករណ៍ណាមួយ ទាក់ទងនឹងភាពទទួលយកបាននៃសំណើសុំធ្វើមោឃភាព នោះឡើយ។

20. អនុលោមតាមវិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះមានយុត្តាធិការក្នុងការសម្រេចលើភាពទទួលយកបាននៃសំណើសុំធ្វើមោឃភាព ដែលអង្គបុរេអាចប្រកាសថាពាក្យសុំមោឃភាពនោះមិនអាចទទួលយកបាន ប្រសិនបើ ក) ពាក្យសុំ មានពាក់ព័ន្ធជាមួយដីកាដែលត្រូវប្តឹងឧទ្ធរណ៍ ខ) ពាក្យសុំ គ្មានមូលដ្ឋានច្បាស់លាស់ ឬ គ) ពាក្យសុំ គ្មានសំអាងហេតុគ្រប់គ្រាន់[34]។

21. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណើសុំធ្វើមោឃភាព មានគោលដៅសុំឱ្យចាត់ទុកជាមោឃៈ

---

[30] ការឆ្លើយតបទៅនឹងចម្លើយតប កថាខណ្ឌ ១០។

[31] យោងដូចខាងលើ។

[32] ការឆ្លើយតបទៅនឹងចម្លើយតប កថាខណ្ឌ ១១, ១២។

[33] *សូមមើលខាងលើ* កថាខណ្ឌ ១៥ និងកំណត់សម្គាល់ជើងទំព័រ ២៨។

[34] សាលដីការបស់អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះ ឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D165/2/26 កថាខណ្ឌ ៥៥។

នូវកិច្ចស៊ើបសួរមួយចំនួន ដែលត្រូវបានចោទប្រកាន់ថាមានភាពមិនប្រក្រតី ក្នុងនោះរួមមាន កំណត់ហេតុស្តាប់ចម្លើយសាក្សីមួយចំនួន ព្រមទាំង ខ្សែអាត់សំឡេង និងប្រតិចារឹកកិច្ចសម្ភាសន៍ ជាមួយសាក្សី។ អង្គបុរេជំនុំជម្រះ សង្កេតឃើញដែរថា សំណើសុំធ្វើមោឃភាពនេះ គ្មានជាប់ពាក់ព័ន្ធនឹងដីកា ឬ សេចក្តីសម្រេច ដែលអាចបើកផ្លូវប្តឹងឧទ្ធរណ៍ ស្របតាមខ្លឹមសារនៃវិធាន ៧៤(៣) នោះទេ។ ក្រៅពីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានលក្ខណៈប្រចក្ស ឬ ច្បាស់ក្រឡែត បញ្ជាក់ថា សំណើសុំធ្វើមោឃភាពនេះ គ្មានមូលដ្ឋាន ទាំងផ្នែកអង្គច្បាប់ និង អង្គហេតុ រហូតធ្វើឱ្យវាមិនអាចត្រូវទទួលយកបាននោះឡើយ ហើយអង្គបុរេយល់ឃើញទៀតថា សំណើសុំនេះមាន សំអាងហេតុគ្រប់គ្រាន់។ សហមេធាវីបានបង្ហាញនូវសំអាងហេតុមួយ គាំទ្រដោយទឡ្ហីករណ៍ផ្លូវច្បាប់ និង ធាតុផ្សំអង្គហេតុ ក្នុងសំណុំរឿង ដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់ ដើម្បីគាំទ្រដល់ការបញ្ជាក់ឱ្យឃើញអំពីកំហុសនីតិវិធី ទាក់ទងនឹងការក្លែងបន្លំដែលរងការចោទប្រកាន់[35] ក៏ដូចជាព្យសនកម្ម ដែលអ្នកស្នើសុំ បានទទួលរង[36]។

22. ដូច្នេះ អង្គបុរេជំនុំជម្រះសូមប្រកាសថា សំណើសុំធ្វើមោឃភាពអាចទទួលយកបាន អនុលោមតាមវិធាន ៧៦(៤)។ អង្គបុរេជំនុំជម្រះ មិនសម្រេចលើភាពទទួលយកបាន នៃសេចក្តីបន្ថែមនោះទេ ដែលវាពាក់ព័ន្ធតែនឹងការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ហើយដែលសំណើសុំធ្វើមោឃភាពការស្តាប់ចម្លើយសាក្សីរូបនេះ មិនត្រូវបានសហចៅក្រមស៊ើបអង្កេត បញ្ជូនទៅអង្គបុរេជំនុំជម្រះនោះទេ[37]។

## V. ការពិចារណាលើអង្គសេចក្តី

23. បន្ទាប់ពីពិភាក្សារួចមក អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងភាគច្រើនតាមតម្រូវការដើម្បីធ្វើសេចក្តីសម្រេចទៅលើសំណើសុំមោឃភាពនេះបានឡើយ។ អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង មតិយោបល់របស់ចៅក្រមនានារបស់អង្គបុរេជំនុំជម្រះ មានភ្ជាប់មកជាមួយនឹងសេចក្តីពិចារណាទាំងនេះ។

---

[35] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ២៧-៣២។

[36] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៤១-៤៦។

[37] *សូមមើល* សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៣៧-៤០, ៤៥-៤៦, ដីកាសម្រេចបញ្ជូនសំណើសុំ កថាខណ្ឌ ២៥-២៧, ៥១-៥៥, ៥៧។

## VI. ផ្នែកសម្រេចសេចក្ដី

**ផ្អែកតាមសំអាងហេតុនេះ អង្គបុរេជំនុំជម្រះ ជាឯកច្ឆ័ន្ទ៖**

- **បដិសេធ** សំណើឧបត្ថម្ភហេតុ។
- **យល់ឃើញ** ថា សំណើសុំមោឃភាពនេះអាចទទួលយកបាន។
- **ប្រកាស** ថា អង្គបុរេជំនុំជម្រះមិនអាចស្វែងរកសម្លេងគាំទ្រពីចៅក្រមយ៉ាងតិច ៤ (បួន) សម្លេង ដើម្បីធ្វើសេចក្ដីសម្រេចលើអង្គសេចក្ដីនៃសំណើសុំមោឃភាពនេះបានទេ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។ អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងភាគច្រើនតាមតម្រូវការ ដើម្បីធ្វើសេចក្ដីសម្រេចលើអង្គសេចក្ដីបានឡើយ។ ដូច្នេះ កិច្ចស៊ើបសួរដែលត្រូវបានស្នើសុំឲ្យមោឃភាពនោះ ត្រូវតម្កល់ទុកជាបានការ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

E.C.C.C. ✲ C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

| ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម |
|---|---|---|---|---|
| **ប្រាក់ គីមសាន** | **Olivier BEAUVALLET** | **ន័យ ថុល** | **Kang Jin BAIK** | **ហួត វុទ្ធី** |

ចៅក្រម **ប្រាក់ គីមសាន** ចៅក្រម **ន័យ ថុល** និងចៅក្រម **ហួត វុទ្ធី** ភ្ជាប់បន្ថែមនូវមតិយោបល់របស់ខ្លួន។

ចៅក្រម **Oliver BEAUVALLET** និងចៅក្រម Kang Jin BAIK ភ្ជាប់បន្ថែមនូវមតិយោបល់របស់ខ្លួន។

# មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន, ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ទាក់ទងនឹងអង្គសេចក្តីនៃពាក្យសុំ

## ក. ការផ្សព្វផ្សាយសេចក្តីពិចារណា

24. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ (“អ.វ.ត.ក”) នឹងបង្ហាញអំពីមតិយោបល់របស់ខ្លួនទាក់ទងនឹងពាក្យសុំរបស់លោកស្រី អ៊ឹម ចែម។ យ៉ាងណាក៏ដោយ ជាការចាប់ផ្តើម យើងសូមធ្វើការបញ្ជាក់អំពីការយល់ឃើញរបស់យើងចំពោះការផ្សព្វផ្សាយជាសាធារណៈនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ។

25. អនុលោមតាមមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក ផ្តល់សិទ្ធិឲ្យ អ៊ឹម ចែម អាចស្នើសុំអង្គបុរេជំនុំជម្រះធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញជា “សាធារណៈ” នូវឯកសារ “សំងាត់” ឬ “សំងាត់បំផុត” ដោយអនុលោមតាមបទប្បញ្ញត្តិនៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង។

26. មាត្រា ៣.១២ វាក្យខណ្ឌទី២ នៃសេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក បានចែងថា “តាមករណីសមស្រប ទាល់តែមានការចេញដីកាដំណោះស្រាយ និងសេចក្តីសម្រេចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ទើបសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះត្រូវពិនិត្យពិចារណា ថាតើចំណាត់ថ្នាក់ប្រភេទឯកសារដែលបានស្នើសុំនោះមានលក្ខណៈសមស្របដែរឬទេ ហើយបើសិនជាមិនសមស្របទេ ត្រូវធ្វើសេចក្តីសម្រេចថាតើចំណាត់ប្រភេទអ្វីទើបសមស្រប”។

27. ផ្អែកតាមទម្លាំករណ៍ខាងលើ ចៅក្រមជាតិ យល់ឃើញថា ការធ្វើចំណាត់ថ្នាក់ឯកសារ “សម្ងាត់” ទៅជា “សាធារណៈ” នៅពេលនេះ គឺពុំទាន់មានភាពចាំបាច់ ហើយក៏មិននាំឲ្យប៉ះពាល់សិទ្ធិ និងផលប្រយោជន៍របស់ អ៊ឹម ចែម ដែរ ព្រោះទោះបីឯកសារនោះជាប្រភេទ “ឯកសារសម្ងាត់” ក៏គាត់អាចមើលឯកសារទាំងនោះបានដែរ។ ហេតុដូចនេះ អង្គបុរេជំនុំជម្រះ គប្បីពិចារណាលើការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ នៅពេលចេញដីកាដំណោះស្រាយ និងសេចក្តីសម្រេចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ អនុលោមតាមមាត្រា ៣.១២ វាក្យខណ្ឌទី២ នៃសេចក្តីណែនាំអនុវត្ត អ.វ.ត.ក។

## ខ.ឧទ្ទិករណ៍របស់ភាគី

28. សហមេធាវីការពារក្តី អ៊ឹម ចែម បានលើកទទ្ទិករណ៍ថា វិធាន ២១(៣) និងវិធាន ៣៥ នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ពីការហាមប្រាម នូវការជ្រៀតជ្រែតលើសាក្សីនានា ឬ សាក្សីដែលនឹងត្រូវកោះហៅ ឬការប៉ុនប៉ងប្រព្រឹត្តនូវអំពើនេះ។ នៅក្នុងសំណុំរឿង ០០៤ មានភស្តុតាងបង្ហាញថា យ៉ាងហោចណាស់ ក៏មានសាក្សីម្នាក់ដែរ ដែលពាក់ព័ន្ធដោយផ្ទាល់នឹងអ្នកស្រី អ៊ឹម ចែម គឺសាក្សី ប៉ោ បណ្តែត ត្រូវបានស្កាត់ជួបដោយអ្នកស៊ើបសួរម្នាក់ ឬ ច្រើននាក់ ទាំងគ្មានដីកាចាត់ឲ្យស៊ើបសួរជំនួសឡើយ។ បញ្ហានេះ ត្រូវបានបញ្ជូនទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ("អយ្យការ") អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[38]។

29. សហមេធាវីការពារក្តី អ៊ឹម ចែម បានធ្វើការបញ្ជាក់ថា ក្រៅពីសាក្សី ប៉ោ បណ្តែត មានសាក្សីពីររូបទៀត គឺសាក្សី ធិប សំផាត់ និងសាក្សី យក់ នាម ដែលជាសក្សីមានការពាក់ព័ន្ធដោយផ្ទាល់នឹងអ្នកស្រី អ៊ឹម ចែម ក៏ត្រូវបានបង្ហាញឲ្យដឹងថា មានការស្កាត់ជួបសួរនាំដោយជនមិនស្គាល់អត្តសញ្ញាណមួយចំនួន។ កិច្ចស៊ើបអង្កេតលើការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការត្រូវបានបើកនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយក្នុងបរិបទនេះ មានការសន្និដ្ឋានថា "ការស៊ើបអង្កេតនេះ នឹងមិនអាចធ្វើទៅកើតទេ វាទាល់តែ [បេសសកម្មនៃការស៊ើបសួរលើករណីនៃការជ្រៀតជ្រែតនេះ] បង្ហាញឲ្យឃើញថាមានសកម្មភាពស៊ើបសួរភាគច្រើនត្រូវបានគ្របដណ្តប់នៅក្រៅក្របខណ្ឌច្បាប់ ហើយថាឯកសារផ្លូវការមួយចំនួន (កំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់សាក្សី) ដែលពាក់ព័ន្ធទៅនឹងការស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌនានា ត្រូវបានរកឃើញថា ធ្វើឡើងដោយការក្លែង"[39]។

30. សហមេធាវីការពារក្តី អ៊ឹម ចែម បានលើកឡើងថា វិធាន ៥៥(៥) ចែងថា ការពិតមួយអាចនឹងរកឃើញបាន លុះណាតែការចងចាំរបស់សាក្សីនូវព្រឹត្តការណ៍នានា គឺជារឿងដែលបានកើតឡើង និងដឹងដោយខ្លួនឯងផ្ទាល់ និងឥតក្លែងបន្លំ។ អង្គជំនុំជម្រះសាលាដំបូងបានហាមប្រាម នូវការសួរសំណួរនាំមុខទៅកាន់សាក្សី នៅអំឡុងពេលធ្វើសវនាការ។ ដូច្នេះ បើទោះជាមិនមានយុត្តិកម្មដែល

---

[38] សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារិត និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីមួយចំនួន ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦, កថាខណ្ឌ ៣០ ឯកសារ D298 ("សំណើសុំ")។

[39] សំណើសុំ កថាខណ្ឌ ៣១។

01340790



បច្ចេកទេសបែបនោះ ត្រូវបានទទួលយក ប្រើប្រាស់ដោយអ្នកស៊ើបសួររបស់ ក.ស.ច.ស នៅពេលស្តាប់ចម្លើយសាក្សីក៏ដោយ ក៏ភស្តុតាងដែលបានតាមរយៈការជំរុញដើម្បីឲ្យបានទទួលនូវចម្លើយតបដែលខ្លួនចង់បាននេះ ធ្វើឲ្យមានការប្រឡាក់ប្រឡូកដល់ភស្តុតាងក្រោយៗទៀតរបស់សាក្សី។ កង្វល់កើតចេញពីការអនុវត្តការស្តាប់ចម្លើយសាក្សីដោយអ្នកស៊ើបសួររបស់ ក.ស.ច.ស ត្រូវបានលើកឡើងនៅក្នុងសំណុំរឿង ០០២ ជាក់ស្តែង នង សុផង់ ដែលគាត់ក៏ជាសាក្សីម្នាក់ផងដែរនៅក្នុងសំណុំរឿង ០០៤។ សាក្សីរូបនេះ បានចង្អុលបង្ហាញថា គាត់មានអារម្មណ៍ថា គាត់ត្រូវបានរំខានពីអ្នកស៊ើបសួរក្នុងអំឡុងពេលកំពុងផ្តល់បទសម្ភាសន៍[40]។

31. សហមេធាវីការពារក្តី អ៊ឹម ចែម បានលើកឡើងបន្ថែមថា តួនាទីជាក់លាក់របស់សាក្សីក្នុងដំណើរការនៃកិច្ចស៊ើបសួររបស់តុលាការ គឺជាបុគ្គលដែលឃើញ ឬបានដឹងឮនូវព្រឹត្តិការណ៍អ្វីមួយ ផ្ទុយពីភាគីជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ដែលមានមុខងារថ្លែងបញ្ជាក់ថា សក្ខីកម្មរបស់សាក្សីត្រូវតែបានទទួលពីការស្តាប់ដោយអ្នកស៊ើបសួររបស់ ក.ស.ច.ស នូវរាល់ការចងចាំពីព្រឹត្តិការណ៍នានារបស់ពួកគេ ជាជាងការសួរយកចម្លើយ។ ចំណុចនេះត្រូវបានបង្ហាញដោយពាក្យពេចន៍នៃវិធានផ្ទៃក្នុងដែលចែងថា សហចៅក្រមស៊ើបអង្កេត "អាចស្តាប់ចម្លើយ" ពីសាក្សី ប៉ុន្តែត្រូវ "សួរចម្លើយ" ជនត្រូវចោទ[41]។

32. សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា ខណៈដែល សពអ ទទួលស្គាល់ថា ការទាក់ទងណាមួយជាមួយសាក្សីរូបនេះ នៅក្រៅក្របខណ្ឌនៃកិច្ចស៊ើបសួររបស់ កសចស ពាក់ព័ន្ធនឹងបញ្ហានានានៅក្រោមកិច្ចស៊ើបសួរ គឺជាមូលហេតុមួយដែលត្រូវខ្វល់ខ្វាយក៏ដោយ ក៏វាហាក់ដូចជាគ្មានភស្តុតាងដែលថាសាក្សី យក់ នាម បានកែ ឬប្តូរសក្ខីកម្មរបស់គាត់នៅក្រោយការជួបទាក់ទងក្រៅកំណត់ហេតុដោយ "បុគ្គលដែលគេមិនស្គាល់" ដែលបានកើតឡើងនៅចន្លោះថ្ងៃទី២៩ ខែកក្កដា និងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១១ ដែរ ("ទំនាក់ទំនងគ្មានការអនុញ្ញាត")។ ពាក្យសុំមោឃភាពពឹងផ្អែកលើការស្មាន ចំពោះអ្វីដែលទំនាក់ទំនងគ្មានការអនុញ្ញាតពាក់ព័ន្ធ និងមិនបានធ្វើសេចក្តីយោងទៅរកខ្លឹមសារនៃភស្តុតាងនៅលើកំណត់ហេតុនោះទេ[42]។

---

[40] សំណើសុំ, កថាខណ្ឌ ៣៣។

[41] សំណើសុំ, កថាខណ្ឌ ៣៤។

[42] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងពាក្យសុំមោឃភាពរបស់ អ៊ឹម ចែម ចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦, កថាខណ្ឌ ៦ , ឯកសារ D298/2/1/1 ("ចម្លើយតប")។

33. សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថា សេចក្តីសម្រេចរបស់ កសចស និងឧបសម្ព័ន្ធរបស់វា បង្ហាញថាកំហុសដែលបានចោទប្រកាន់ដោយ អ៊ឹម ចែម ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត គឺ "ទំនងណាស់ជាកំហុសបច្ចេកទេស" គឺកំណត់ហេតុស្តាប់ចម្លើយសាក្សីត្រួតដែលចុះកាលបរិច្ឆេទខុសគ្នា ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង។ ដូចដែលបានកត់សម្គាល់ដោយ កសចស ទោះបីជាកំណត់ហេតុស្តាប់ចម្លើយមួយចុះកាលបរិច្ឆេទនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ និងមួយផ្សេងទៀត នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១១ ក៏ដោយ ក៏កំណត់ហេតុនោះ "មានខ្លឹមសារដូចគ្នា"[43]។

34. សហព្រះរាជអាជ្ញាអន្តរជាតិ បានបញ្ជាក់ថា សិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីមួយត្រឹមត្រូវ និងមិនលំអៀងរបស់ អ៊ឹម ចែម មិនត្រូវបានរំលោភទេ។ អ៊ឹម ចែម ទំនងជាចោទប្រកាន់ពីភាពលំអៀងជាសត្យានុម័តទៅខាងផ្នែកអ្នកស៊ើបអង្កេតរបស់ កសចស ប៉ុន្តែខកខានមិនបានកំណត់អត្តសញ្ញាណកម្ម ថាតើគាត់បានធ្វើការចោទប្រកាន់បែបដូច្នេះដោយប្រឆាំងនឹងអ្នកស៊ើបអង្កេតដែល "លំអៀង" ជាក់លាក់ ឬមួយក៏ កសចស ទាំងមូល ទាក់ទងទៅនឹងការស៊ើបអង្កេតរបស់គាត់។ នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ អ៊ឹម ចែម បានខកខានមិនបានចង្អុលទៅភស្តុតាងណាមួយដែលនឹងត្រូវលើកឡើងពីក្តីមន្ទិលទាក់ទងនឹងភាពមិនលំអៀងរបស់អ្នកស៊ើបអង្កេតរបស់ កសចស នៅក្នុងករណីរបស់គាត់នោះទេ[44]។

## គ. អង្គច្បាប់

35. វិធាន ៧៦ (២) នៃវិធានផ្ទៃក្នុងកំណត់ថា "ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតប្តឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឲ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួលយក ឬបដិសេធសំណើសុំភ្លាមៗតាមតែអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ រីឯវិធាន ៤៨ នៃវិធានផ្ទៃក្នុង ចែងថា "កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធាន

[43] ចម្លើយតប, កថាខណ្ឌ ១១។

[44] ចម្លើយតប, កថាខណ្ឌ ១៣។

បញ្ញត្តិ ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។

36. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា អ.វ.ត.ក ត្រូវបានបង្កើតឡើងតាម កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង), ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ច្បាប់ អ.វ.ត.ក) និងអនុវត្តវិធានផ្ទៃក្នុង។

37. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរ ខុសពីតុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា។ ការចោទប្រកាន់ និងការស៊ើបសួររបស់តុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា គឺធ្វើឡើងតែលើអង្គហេតុទេ មានន័យថាមិនមែនជាការចោទប្រកាន់ និងការស៊ើបសួរលើបុគ្គលឡើយ[45]។ ផ្ទុយមកវិញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចោទប្រកាន់ និងការស៊ើបសួរ អាចធ្វើទៅបាន លុះត្រាបំពេញលក្ខខណ្ឌពីរ គឺ ទី១.***អង្គហេតុ*** "ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩" និង ទី២.***បុគ្គល*** "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[46]។

38. ហេតុដូច្នេះចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណា ថាតើកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងកំណត់ហេតុស្តាប់ចម្លើយ បំពាននូវលក្ខខណ្ឌដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទី១៤ ដែលនាំឲ្យមិនគោរពវិធានបញ្ញត្តិនៃការស៊ើបសួរដូចដែលបានពន្យល់នៅក្នុងកថាខណ្ឌ ១២ ខាងលើ ជាហេតុធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ អ៊ឹម ចែម និងនាំឲ្យ

---

[45] មាត្រា ៤៤ និង ១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[46] មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធាន ៥៣ នៃវិធានផ្ទៃក្នុង។

មោឃៈ ដែរ ឬទេ។

39. សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានខ្វែងយោបល់គ្នាចំពោះការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៤ នេះ ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣។ រីឯសហព្រះរាជអាជ្ញាជាតិបានបដិសេធចោលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ ផ្អែកលើមូលដ្ឋាន "ជនសង្ស័យទាំងនេះ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត"[47] ហើយចៅក្រមជាតិ និងអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ក៏បានខ្វែងយោបល់គ្នាចំពោះបញ្ហានេះដែរ ដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ គាំទ្រទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាជាតិ[48]។

40. តាមការយល់ឃើញខាងលើចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថាប្រតិចារឹក និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី គប្បីត្រូវមោឃភាពតាមសំណើសុំរបស់មេធាវីការពារក្តី។

**រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ តុលា ឆ្នាំ២០១៦**

**ប្រាក់ គឹមសាន** **ន័យ ថុល** **ហួត វុទ្ធី**

[47] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឱ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០៩ កថាខណ្ឌទី ៨៦ (ក)។

[48] យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ "អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"។

## មតិយោបល់របស់ចៅក្រម BEAUVALLET និងចៅក្រម BAIK
## (“ចៅក្រមដែលបានចុះហត្ថលេខា”)

### I. ច្បាប់ជាធរមាន

41. វិធាន ៧៣(ខ) នៃវិធានផ្ទៃក្នុង ចែងអំពីសមត្ថកិច្ចផ្ដាច់មុខរបស់អង្គបុរេជំនុំជម្រះ ក្នុងការសម្រេចលើសំណើសុំមោឃភាព។

42. ចៅក្រមដែលបានចុះហត្ថលេខា សូមរំឭកថា អនុលោមតាមវិធាន ៤៨ ការពិនិត្យលើសំណើសុំមោឃភាព ចែកជាពីរដំណាក់កាលបន្តបន្ទាប់គ្នា៖ ១) ជាបឋម ការពិនិត្យលើកំហុសនីតិវិធី ២) បន្ទាប់មក ប្រសិនបើមានកំហុសនីតិវិធី ពិតប្រាកដមែន អត្ថិភាពនៃព្យសនកម្ម ចំពោះអ្នកស្នើសុំ។ ហេតុដូច្នេះ កំហុសនីតិវិធី ដែលមិនបង្កផលប៉ះពាល់ដល់ភាគីស្នើសុំ នឹងមិនតម្រូវឱ្យមានការធ្វើមោឃភាពនោះឡើយ[49]។

### II. ឧឡារិករណ៍របស់ភាគី

43. អនុលោមតាមវិធាន ២១(៣) និងវិធាន ៣៥ នៃវិធានផ្ទៃក្នុង សហមេធាវីស្នើសុំធ្វើមោឃភាពការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ដែលទំនងជាត្រូវបានស្ដាប់ចម្លើយ ដោយអ្នកស៊ើបអង្កេតម្នាក់ ឬច្រើននាក់ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយគ្មានដីកាចាត់ឱ្យស៊ើបសួរជំនួស[50] និងការស្ដាប់ចម្លើយសាក្សី យក់ នាម ដែលទំនងជាត្រូវបានទាក់ទងក្រៅផ្លូវការ ដោយបុគ្គលមួយចំនួនដែលមិនស្គាល់អត្តសញ្ញាណ[51]។ សហមេធាវីផ្អែកជាពិសេសលើការ “មានហេតុផលជឿជាក់” របស់ចៅក្រម KASPER-ANSERMET នៅពេលដែលគាត់បញ្ជូនសំណុំរឿងនេះ ទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ថាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ “ដោយបុគ្គលច្រើននាក់ ដែលធ្វើការ ឬដែលធ្លាប់ធ្វើការនៅ អ.វ.ត.ក ដោយពួកគេមាន

---

[49] សំណុំរឿង ០០៣ (អបជ ២០) សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើឱ្យអង្គបុរេជំនុំជម្រះ ទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D134/1/10 (“សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត”) កថាខណ្ឌ ២៤-២៥។

[50] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៣០។

[51] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៣១ *យោងទៅ* សេចក្ដីសម្រេចបើកការស៊ើបអង្កេត។

ជាប់ពាក់ព័ន្ធនឹងការក្លែងបន្លំឯកសារ និងបានព្យាយាមបង្វែងដានការស៊ើបសួរ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឱ្យងាកចេញពីសាក្សីសក្ដានុពលម្នាក់" ពោលគឺ "សាក្សី ទុំ សឿន ដែលសក្ខីកម្មរបស់គាត់ ពិតជាសំខាន់ក្នុងការស្វែងរកការពិត នៅក្នុងសំណុំរឿង ០០៤"[52]។

44. សហមេធាវីលើកឡើងថា សិទ្ធិរបស់អ្នកស្នើសុំក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងដោយស្មោះត្រង់ ដោយតុលាការមិនលម្អៀង ត្រូវបានរងផលប៉ះពាល់ ដោយសារថាសុចរិតភាពនៃដំណើរការនីតិវិធី ក្នុងការប្រមូលភស្តុតាងប្រឆាំងនឹងអ្នកស្នើសុំ ត្រូវបានចោទជាបញ្ហា ដោយសារមានកំហុសនីតិវិធីធ្ងន់ធ្ងរ[53]។ សហមេធាវីលើកឡើងថា ទោះបីជានៅពេលក្រោយមកទៀត សាក្សីទាំងនេះត្រូវបានស្ដាប់ចម្លើយឡើងវិញក៏ដោយ ក៏ការចងចាំរបស់ពួកគាត់ពីព្រឹត្តិការណ៍នានា ពិតជាត្រូវបានរងភាពប្រឡូកប្រឡាក់[54] ហើយវាមានហេតុផលស្របច្បាប់ ដែលត្រូវបារម្ភអំពីកង្វះភាពមិនលម្អៀងរបស់អ្នកស៊ើបអង្កេត[55]។ ម្យ៉ាងវិញទៀត សហមេធាវីលើកឡើងថា សិទ្ធិក្នុងការរៀបចំយ៉ាងមានប្រយោជន៍ នូវការការពារក្ដី និងការសួរដេញដោលសាក្សីប្រឆាំងនឹងកូនក្ដីរបស់ខ្លួនតម្រូវសម្រាប់អ្នកស្នើសុំថា រាល់ភស្តុតាងទាំងអស់ ដែលត្រូវបានដាក់បង្ហាញដល់ខ្លួន មានរួមទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ត្រូវតែពិតប្រាកដ មិនក្លែងក្លាយ[56] និងពុំមែនជាការផ្ទុះបញ្ចាំងពីទស្សនៈអត្តនោម័តិរបស់អ្នកស៊ើបអង្កេតនោះឡើយ[57]។

45. ជាចុងក្រោយ សហមេធាវីបន្ថែមថា ការស៊ើបអង្កេតលើបទជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ នៅតែបន្តធ្វើពុំចេះចប់ ហើយថា សហចៅក្រមស៊ើបអង្កេតពុំបានប្ដឹងអង្គបុរេជំនុំជម្រះ ឱ្យពិនិត្យលើសំណើសុំធ្វើមោឃភាពណាមួយនោះទេ[58]។ ហេតុដូច្នេះ រាល់ភស្តុតាងដែលត្រូវបានរាយការណ៍ដោយ ប៉ោ បណ្ដែត និង យក់ នាម មាននៅក្នុងសំណុំរឿងជានិច្ច ហើយអាចត្រូវបានប្រើប្រាស់គ្រប់ពេលវេលា ប្រឆាំងនឹងអ្នកស្នើសុំ[59]។ ដំណោះស្រាយសមស្របតែមួយគត់

---

[52] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៣០ *យោងទៅ* ដីកាសម្រេចបញ្ជូនទៅអយ្យការ កថាខណ្ឌ ៦៨។

[53] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៤១។

[54] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៣២, ៤២។

[55] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៤២។

[56] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៤៤។

[57] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៤៥, ៤៦។

[58] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៤២។

[59] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៤២, ៤៣។

គឺត្រូវចាត់ទុកជាមោឃៈ នូវរាល់កិច្ចស៊ើបសួរដែលមានកំហុស ព្រមទាំងនីតិវិធីក្រោយៗ មួយចំនួនទៀតដែលរងផលប៉ះពាល់ ផងដែរ[60]។

46. សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបថា ទោះបីជាការណ៍ដែលសាក្សីមួយចំនួន ត្រូវបានទាក់ទងនៅក្រៅក្របខណ្ឌនៃកិច្ចដំណើរការនីតិវិធីស្របច្បាប់ គឺជាមូលហេតុនៃក្ដីបារម្ភក៏ដោយ ក៏ក្នុងករណីជាក់ស្ដែងនេះ វាគ្មានកំហុសនីតិវិធីនោះទេ ព្រោះថា គ្មានភ័ស្តុតាងបង្ហាញថា យក់ នាម បានកែប្រែសក្ខីកម្មរបស់គាត់ ក្រោយពីមានការទាក់ទងដែលមានភាពចម្រូងចម្រាសនោះដែរ[61]។ សហព្រះរាជអាជ្ញាអន្តរជាតិគូសបញ្ជាក់ថា សាក្សីរូបនេះបានរក្សាចម្លើយដូចគ្នា ទាក់ទងនឹងអង្គហេតុឧក្រិដ្ឋ ក្នុងអំឡុងពេលស្ដាប់ចម្លើយទាំងអស់របស់គាត់[62]។ ដូចគ្នានេះដែរ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា កំហុសនីតិវិធីដែលរងការចោទប្រកាន់ ពាក់ព័ន្ធនឹង ប៉ោ បណ្ដែត អាចត្រូវគ្នានឹងកំហុសជាក់ស្ដែង[63]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា សិទ្ធិរបស់អ្នកស្នើសុំមិនត្រូវបានរំលោភឡើយ ហើយអ្នកស្នើសុំពុំបានចង្អុលបង្ហាញភ័ស្តុតាងណាមួយ ដើម្បីដាក់មន្ទិលសង្ស័យលើភាពមិនលម្អៀងរបស់អ្នកស៊ើបអង្កេត នោះឡើយ[64]។

47. សហមេធាវីឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាថា មន្ទិលសង្ស័យទាក់ទងនឹងភាពមិនលម្អៀងនៃកិច្ចស៊ើបសួរ ត្រូវបានបញ្ជាក់តាមរយៈការបើកកិច្ចស៊ើបអង្កេត អនុលោមតាមវិធាន ៣៥ ហើយច្បាស់ណាស់ថា សាក្សីមួយចំនួនត្រូវបានទាក់ទងក្រៅផ្លូវការ ដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត[65]។ គ្រាន់តែការណ៍ដែលកិច្ចស៊ើបអង្កេតចំហមួយត្រូវបានបើកធ្វើ អនុលោមតាមវិធាន ៣៥ ហើយដែលមិនទាន់ត្រូវបានបិទបញ្ចប់នោះ គឺវាបានរំលោភដល់សិទ្ធិរបស់អ្នកស្នើសុំ ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងតម្លាភាព រួចស្រេចទៅហើយ[66]។

---

[60] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៤៨ *យោងទៅ* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ២៧។

[61] ចម្លើយតប កថាខណ្ឌ ៦។

[62] ចម្លើយតប កថាខណ្ឌ ៧-៩, ១៤។

[63] ចម្លើយតប កថាខណ្ឌ ១១ *យោងទៅ* ដីកាសម្រេចបញ្ជូនសំណើសុំ កថាខណ្ឌ ៤០។

[64] ចម្លើយតប កថាខណ្ឌ ១៣។

[65] ការឆ្លើយតបទៅនឹងចម្លើយតប កថាខណ្ឌ ៩។

[66] ការឆ្លើយតបទៅនឹងចម្លើយតប កថាខណ្ឌ ៩។

## III. ការពិភាក្សាសម្រេច

48. ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ពីភាពមិនជឿជាក់ និងមន្ទិលសង្ស័យជាច្រើន ទាក់ទងនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដែលត្រូវបានលើកឡើងក្នុងអំឡុងពេលនៃការស៊ើបអង្កេតផ្ទៃក្នុង នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយដែលត្រូវបានបញ្ជូនទៅអាជ្ញាធរកម្ពុជា ដើម្បីសុំសេចក្តីសម្រេច។ ដោយផ្អែកលើមូលដ្ឋានភស្តុតាងនានា ដែលមានក្នុងសំណុំរឿង និងដោយមិនគិតពីកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ទាក់ទងនឹងការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដូចដែលត្រូវបានរងការចោទប្រកាន់ ចៅក្រមដែលបានចុះហត្ថលេខានឹងយកចិត្តទុកដាក់តែទៅលើការកំណត់ថា តើការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹង ប៉ោ បណ្ដែត និង យក់ នាម មានមូលហេតុត្រឹមត្រូវ ស្របតាមវិធាន ៤៨ ដែរឬទេ។

### ក. កិច្ចស៊ើបសួរពាក់ព័ន្ធនឹងសាក្សី ប៉ោ បណ្ដែត

49. សហមេធាវីលើកឡើងថា កិច្ចស៊ើបសួរទាក់ទងនឹង ប៉ោ បណ្ដែត មានកំហុស ព្រោះថាសាក្សីហាក់ដូចជាត្រូវបានស្តាប់ចម្លើយនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ពុំមែននៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ នោះទេ ពោលគឺគ្មានដីកាចាត់ឱ្យស៊ើបសួរជំនួស និងធ្វើឡើងដោយអ្នកស៊ើបអង្កេតម្នាក់ ឬ ច្រើននាក់ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត[67]។ ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ថា មានកំណត់ហេតុស្តាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ចំនួនពីរ នៅក្នុងសំណុំរឿង និងមានការចុះកាលបរិច្ឆេទខែ សីហា និង កញ្ញា ឆ្នាំ ២០១១ ហើយដែលខ្លឹមសារដើមជាភាសាខ្មែរ នៃកំណត់ហេតុទាំងពីរនោះ ដូចគ្នា លើកលែងតែចំណុចបីដែលខុសគ្នា នោះគឺ កាលបរិច្ឆេទនៃការស្តាប់ចម្លើយ ទីកន្លែងស្តាប់ចម្លើយ ព្រមទាំង ហត្ថលេខា និងស្នាមម្រាមដៃរបស់សាក្សី។

*កំណត់ហេតុ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១*

50. ចៅក្រមដែលបានចុះហត្ថលេខាសង្កេតឃើញថា កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ មានលក្ខណៈផ្ទុយពីបទប្បញ្ញត្តិនានា ដែលមានចែងនៅក្នុងវិធាន ៥៥(៧) ៥៥(៩) និង ៦២ នៃវិធានផ្ទៃក្នុង ម្យ៉ាង ដោយសារថាគ្មានហត្ថលេខារបស់សាក្សីដែលបានស្តាប់ចម្លើយ ហើយម្យ៉ាងវិញទៀត ដោយសារថា កំណត់ហេតុនេះត្រូវបានចុះកាលបរិច្ឆេទមុនកាល

---

[67] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៣០។

បរិច្ឆេទរបស់ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ដែលបានប្រគល់សិទ្ធិឱ្យធ្វើការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត។ ដូច្នេះ កំណត់ហេតុមួយនេះ ពុំបំពេញបាននូវរាល់ល័ក្ខខ័ណ្ឌ ស្តីពីអត្ថិភាពស្របច្បាប់នៃកំណត់ហេតុ នោះឡើយ។

51. ប៉ុន្តែ ចៅក្រមដែលបានចុះហត្ថលេខាគត់សម្គាល់ថា កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ពុំត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ធ្វើជាភស្តុតាងគាំទ្រដល់ការស៊ើបសួរដែលត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័ស ក្នុងសំណុំរឿង ០០៤ នោះទេ។ កំណត់ហេតុនេះត្រូវបានប្រមូលយក សម្រាប់តម្រូវការជាក់លាក់ នៃការស៊ើបអង្កេតអំពីបញ្ហាជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលអង្គជំនុំជម្រះ ដែលចាប់ផ្តើមធ្វើកាលពីថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ អនុលោមតាមវិធាន ៣៥(២)(ខ) ហើយដែលត្រូវបានដាក់ចូលក្នុងសំណុំរឿង នៅខែ ឧសភា ឆ្នាំ ២០១២ ធ្វើជាឧបសម្ព័ន្ធនៃអនុស្សរណៈផ្ទៃក្នុងមួយ[68] និងជាឧបសម្ព័ន្ធនៃរបាយការណ៍អ្នកស៊ើបអង្កេត ដែលត្រូវបានធ្វើឡើង ដោយអនុវត្តតាមដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២។ ក្នុងន័យនេះ កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ គឺជាភស្តុតាង ពាក់ព័ន្ធនឹងការស៊ើបអង្កេតលើបទជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ និងពុំមែនទាក់ទងនឹងការចោទប្រកាន់ទាំងឡាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿង ០០៤/១ នោះទេ។ ដូច្នេះគ្មានព្យសនកម្មចំពោះអ្នកស្នើសុំឡើយ។

52. ពាក់ព័ន្ធនឹងចំណុចនេះ ចៅក្រមដែលបានចុះហត្ថលេខាសូមរំឭកថា ការកំណត់អំពីអត្ថិភាពនៃការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ តម្រូវឱ្យមានភស្តុតាងបទល្មើសជាក់ស្តែង ចំណែកឯវិញ្ញាសាជាធរមាន ទាក់ទងនឹងសំណើសុំមោឃភាព តម្រូវឱ្យមានភស្តុតាងបង្ហាញពីកំហុសនីតិវិធី និងព្យសនកម្មបង្កឡើង។ បើគ្រាន់តែមានអត្ថិភាពនៃការស៊ើបអង្កេតពីបទជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ គឺមិនអាចកំណត់នូវកំហុសនីតិវិធី ដូចដែលបានលើកឡើង ឬព្យសនកម្មនោះទេ ជាពិសេស ក្នុងករណីដែលការស៊ើបអង្កេត មិនទាន់បានបិទបញ្ចប់។ ម្យ៉ាងវិញទៀត ការបើកកិច្ចស៊ើបអង្កេតលើបទជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ ដែលមិនអាចរំលោភលើសិទ្ធិរបស់អ្នកស្នើសុំ គ្រាន់តែមានគោលដៅធ្វើការផ្ទៀងផ្ទាត់ពីភាពស្មោះត្រង់នៃកិច្ចដំណើរការនីតិវិធី ដែលបានធ្វើឡើងយ៉ាងឆាប់រហ័ស ប្រឆាំងនឹងរូបគាត់ ប៉ុណ្ណោះ។

[68] អនុស្សរណៈអន្តរការិយាល័យ ផ្ញើដោយអ្នកស៊ើបអង្កេត STOCCHI ទៅកាន់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង KASPER-ANSERMET ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ D85/5។

53. ដូច្នេះ ចៅក្រមដែលបានចុះហត្ថលេខាសូមបដិសេធសំណើសុំមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ (D85/5.1.4.2) និងក្រោមហេតុផលដូចគ្នានេះ បដិសេធសំណើសុំមោឃភាពប្រតិចារឹកនៃកំណត់ហេតុនេះ (D85/4.1.5) ដែលត្រូវបានដាក់បញ្ចូលផងដែរ ទៅក្នុងសំណុំរឿង ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតលើបទជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ។ ឯកសារទាំងនេះ ពុំអាចមានតម្លៃជាភ័ស្តុតាង ពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយដែលត្រូវបានចោទប្រកាន់ចំពោះអ្នកស្នើសុំ នោះទេ។

*កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១*

54. ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ថា កំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ ដែលត្រូវប្រមូលបាន ក្នុងក្របខណ្ឌនៃសំណុំរឿង ០០៤ ត្រូវបានចុះហត្ថលេខាយ៉ាងត្រឹមត្រូវ ហើយវាត្រូវបានធ្វើឡើង ក្រោយពីមានដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ដែលសម្រេចផ្ទេរសិទ្ធិឱ្យធ្វើការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត។ សហមេធាវីពុំបានចង្អុលបង្ហាញភ័ស្តុតាងជាក់ស្តែងណាមួយក្នុងសំណុំរឿង ដែលអាចបង្ហាញឱ្យឃើញពីកំហុសនីតិវិធីណាមួយនោះទេ ក្រៅតែពីមានមន្ទិលសង្ស័យ ទាក់ទងនឹងបញ្ហាជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ និងកង្វះភាពមិនលម្អៀងរបស់អ្នកស៊ើបអង្កេត។ ទោះបីយ៉ាងណាក៏ដោយ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា ធាតុផ្សំទាំងនេះ ពុំគ្រប់គ្រាន់សម្រាប់បដិសេធចោលនូវការសន្មតទុកជាមុនថាកំណត់ហេតុស្តាប់ចម្លើយសាក្សី មានភាពជឿទុកចិត្តបាន នោះឡើយ[69]។ ចៅក្រមដែលបានចុះហត្ថលេខាសូមធ្វើការគូសបញ្ជាក់ថា កាលៈទេសៈទាំងឡាយ ដែលកើតមាននៅជុំវិញការស្តាប់ចម្លើយសាក្សី នឹងក្លាយជាធាតុផ្សំដែលត្រូវយកមកពិចារណា នៅក្នុងដំណាក់កាលក្រោយមកទៀត ក្នុងអំឡុងពេលធ្វើការវាយតម្លៃលើភ័ស្តុតាង ដោយសហចៅក្រមស៊ើបអង្កេត ដោយអង្គបុរេជំនុំជម្រះ និងដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីបើមានដូច្នេះមែន។

55. លើផ្នែកទម្រង់ កំណត់ហេតុនៃការស្តាប់ចម្លើយនេះ មានភាពប្រក្រតីត្រឹមត្រូវ។ អាស្រ័យហេតុនេះ ចៅក្រមដែលបានចុះហត្ថលេខាសូមបដិសេធចោលសំណើសុំមោឃភាពកំណត់ហេតុនៃការស្តាប់

---

[69] សំណុំរឿង ០០២ (អបជ ៣៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើសុំធ្វើប្រតិចារឹក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១០ ឯកសារ D194/3/2 កថាខណ្ឌ ២១។

ចម្លើយ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ (D101/1.1) ព្រមទាំងខ្សែអាត់សំឡេងនៃកំណត់ហេតុនៃការស្តាប់ចម្លើយនេះ (D101/1.1R)។

## ខ. កិច្ចស៊ើបសួរពាក់ព័ន្ធនឹងសាក្សី យក់ នាម

56. សហមេធាវី ដែលផ្អែកជាពិសេស លើរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីខែ កញ្ញា ឆ្នាំ ២០១១[70] លើកឡើងថា កិច្ចស៊ើបសួរទាក់ទងនឹងសាក្សី យក់ នាម មានកំហុស ព្រោះថា សាក្សីរូបនេះ ទំនងជាត្រូវបានទាក់ទងក្រៅផ្លូវការ ដោយបុគ្គលមួយចំនួន មិនស្គាល់អត្តសញ្ញាណ[71] ក្នុងចន្លោះពេលដែលគាត់ត្រូវបានស្តាប់ចម្លើយ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ ដោយសហចៅក្រមស៊ើបអង្កេត BLUNK និងការស្តាប់ចម្លើយរបស់គាត់ នៅថ្ងៃទី ១២ និង ១៣ ខែ មករា ឆ្នាំ ២០១៥។

57. ចៅក្រមដែលបានចុះហត្ថលេខាសង្កេតឃើញថា ការចោទប្រកាន់នានាពាក់ព័ន្ធនឹងជំនួបក្រៅផ្លូវការមួយនេះ គឺផ្អែកលើសម្តី ដែលគេគិតថាជារបស់ យក់ នាម ហើយដែលត្រូវបានរាយការណ៍ដោយប្រយោល ក្នុងរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា[72] និងក្នុងរបាយការណ៍អ្នកស៊ើបអង្កេត ដែលត្រូវបានធ្វើឡើងក្នុងក្របខណ្ឌនៃការស៊ើបអង្កេតផ្ទៃក្នុង លើបញ្ហាជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលអង្គជំនុំជម្រះ[73]។ ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ផងដែរ ពីកង្វះធាតុផ្សំ ដែលអាចឱ្យគេកំណត់បាននូវអត្តសញ្ញាណរបស់បុគ្គលទាំងបីនាក់ ដែលទំនងជាបានជួបសាក្សី

---

[70] *សូមមើល* របាយការណ៍ចុះពិនិត្យដល់ទីកន្លែង របស់ DC-Cam។

[71] សំណើសុំធ្វើមោឃភាព កថាខណ្ឌ ៣១ *យោងទៅ* ដីកាសម្រេចបើកការស៊ើបអង្កេត។

[72] របាយការណ៍ចុះពិនិត្យដល់ទីកន្លែង របស់ DC-Cam ទំព័រ ២ ("នាម បានប្រាប់យើងថា នៅឆ្នាំ ២០១១ មានមនុស្សពីរក្រុម បានមកសម្ភាសគាត់។ ក្រុមទី១ មានមនុស្សប្រាំមួយនាក់ (បរទេសពីរនាក់ និង ខ្មែរបួននាក់")។ ក្រុមនេះបានអញ្ជើញ នាម ឱ្យទៅកាន់សាលាឃុំភ្នំលាប ហើយបានសម្ភាសគាត់ ពាក់ព័ន្ធនឹង យាយ ចែម។ កិច្ចសម្ភាសន៍លើកទី២ ត្រូវបានធ្វើឡើងដោយមនុស្សបីនាក់ (មានស្ត្រីខ្មែរម្នាក់ និងបរទេសពីរនាក់) ដែលបានមកដល់ផ្ទះរបស់គាត់")។

[73] របាយការណ៍អ្នកស៊ើបអង្កេត ទំព័រ ៣ ("នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ យើងបានជួបជាមួយសាក្សី យក់ នាម ដែលគាត់ធ្លាប់ត្រូវបានសម្ភាសកាលពីលើកមុន ដោយចៅក្រម Blunk នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១ ក្នុងការស៊ើបសួរសំណុំរឿង ០០៤ ជាពិសេស ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំត្រយ៉ូង។ សាក្សីរូបនេះ ក៏បានអះអាងដែរថា ក្រោយមកទៀត ធ្លាប់មានមនុស្សច្រើននាក់ បានទាក់ទងមកគាត់ ក្នុងនោះមាន មនុស្សមួយក្រុម មានស្ត្រីម្នាក់ និងបុរសពីរនាក់ ហើយដែលអ្នកទាំងនោះនិយាយថា ពួកគេមកពី អ.វ.ត.ក ហើយនៅពេលបញ្ចប់កិច្ចសម្ភាសន៍ ពួកគេបានប្រគល់ទស្សនាវដ្តី "ស្វែងរកការពិត" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចំនួនមួយច្បាប់ ជូនដល់សាក្សី")។

ក្រោយពីចៅក្រម BLUNK បានស្តាប់ចម្លើយគាត់ ជាផ្លូវការរួចមក[74]។

58. ទោះយ៉ាងណាក៏ដោយ សាក្សី យក់ នាម បានបញ្ជាក់ក្នុងអំឡុងពេលដែលគាត់ត្រូវបានស្តាប់ចម្លើយជាផ្លូវការ កាលពីថ្ងៃទី ១២ និង ១៣ ខែ មករា ឆ្នាំ ២០១៥ ថា ដំបូងឡើយ គាត់ត្រូវបានស្តាប់ចម្លើយ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងបន្ទាប់មកទៀតដោយបុគ្គលមួយចំនួនមិនស្គាល់ឈ្មោះ និងដែលពួកគេពុំបានកត់ត្រាអ្វីសោះ និងក្រោយមកទៀត ដោយចៅក្រម BLUNK នៅក្នុងខែ កក្កដា ឆ្នាំ ២០១១[75]។ សាក្សីពុំបានលើកឡើងពីសម្ពាធ ឬ ជំនួបណាមួយក្រោយពេលដែលគាត់បានជួបជាមួយចៅក្រម BLUNK នោះទេ ហើយគាត់បានបដិសេធយ៉ាងច្បាស់លាស់ថា គាត់ពុំបានជួបជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បុគ្គលិកស្ថាប័ន SOAS/HRW ឬ បុគ្គលិករបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស នោះទេ[76]។

59. យោងតាមភស្តុតាងទាំងឡាយដែលមាននៅក្នុងសំណុំរឿង ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា គ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់បង្ហាញអំពីកំហុសនីតិវិធី ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការស្តាប់ចម្លើយសាក្សីទាំងអស់ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ១២ និង ១៣ ខែ មករា ឆ្នាំ ២០១៥ នោះឡើយ។ ម្យ៉ាងវិញទៀត ចៅក្រមដែលបានចុះហត្ថលេខាសូមរំឭកថា ការធ្វើមោឃភាពអនុលោមតាមវិធាន ៤៨ ពុំមែនជាដំណោះស្រាយតែមួយគត់ដែលមាននោះទេ ហើយថា កាលៈទេសៈនានា ជុំវិញការប្រមូលយកភស្តុតាង នឹងត្រូវចៅក្រមយកមកពិចារណា ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន នៅដំណាក់កាលចេញដីកាដំណោះស្រាយ ដែលអាចរួមមានអង្គបុរេជំនុំជម្រះផងដែរ និងនៅដំណាក់កាលជំនុំជម្រះ ក្នុងករណីដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

60. សំអាងលើហេតុផលទាំងអស់នេះ ចៅក្រមដែលបានចុះហត្ថលេខាសូមបដិសេធចោលសំណើសុំមោឃភាពកិច្ចស៊ើបសួរទាំងឡាយ ទាក់ទងនឹងសាក្សី យក់ នាម (D219/140 និង D219/141)។

---

[74] អ្នកទាំងបីនាក់នេះ ទំនងជាបានណែនាំខ្លួនឯងថាជាក្រុមការងារមកពីអង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែ ទំនងជាបានប្រគល់ជូនសាក្សី នូវទស្សនាវដ្តីរបស់អង្គភាពមួយផ្សេង។ *សូមមើលជាឧទាហរណ៍* របាយការណ៍អ្នកស៊ើបអង្កេត ទំព័រ ៣ ("ផ្អែកតាមព័ត៌មានដែលប្រមូលបាន ក្នុងអំឡុងពេលបេសកកម្មនេះ វាប្រាកដច្បាស់ណាស់ថា សាក្សីរូបនេះ ត្រូវបានទាក់ទង និងសម្ភាសដោយក្រុមការងាររបស់ អ.វ.ត.ក ឬ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា")។

[75] កំណត់ហេតុ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៣-៤។

[76] យោងដូចខាងលើ។

01340802



61. យោងទៅលើហេតុផលដែលបានបញ្ជាក់ជូនខាងលើ ចៅក្រមដែលបានចុះហត្ថលេខា បដិសេធសំណើសុំមោឃភាពនេះទាំងស្រុង។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦

**Olivier BEAUVALLET** **Kang Jin BAIK**